## 1> ការពង្រាយកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### 1.1- ការធានាសមត្ថភាពជំនាញដល់កូនជាង និងកម្មករ និយោជិត

ការហ្វឹកហ្វឺនកូនជាង ជាការហាត់រៀននៅកន្លែងធ្វើការផ្ទាល់ ហើយជារូបភាពបណ្តុះបណ្តាលមួយមានប្រសិទ្ធភាពខ្ពស់ ព្រោះរាល់សកម្មភាពអនុវត្តបានផ្សារភ្ជាប់ទៅនឹងវិជ្ជាជីវៈជាក់ស្តែង ។ យោងតាមច្បាប់ស្តីពីការងារក្នុងជំពូក៣ស្តីពីការហ្វឹកហ្វឺនកូនជាង និងការធ្វើតេស្តដល់កម្មករនិយោជិត នៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុននានា ឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅធ្វើឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិតនូវមុខទំនិញ តាមតម្រូវការទីផ្សារពិសេសតាមការបញ្ជាទិញរបស់អតិថិជន (Buyers)។

ម្យ៉ាងវិញទៀតក្នុងច្បាប់នេះ ក៏បញ្ជាក់ផងដែរថា សហគ្រាស គ្រឹះស្ថានទាំងឡាយដែលប្រើប្រាស់កម្មករ និយោជិតច្រើនជាង ៦០នាក់ គឺនិយោជក ត្រូវមានកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងស្មើនឹងមួយភាគដប់ ដើម្បីបង្កើនសមត្ថភាពដល់ពួកគេ ឱ្យបានចេះស្ទាត់នូវមុខវិជ្ជាដែលជាតម្រូវការជាក់ស្តែងរបស់សហគ្រាស គ្រឹះស្ថាន ជាពិសេសបំពេញសមត្ថភាពឱ្យពួកគេឆ្លងផុតពីឋានៈកូនជាង ។ ដើម្បីអនុវត្តការងារនេះកាន់តែមានប្រសិទ្ធភាព ក្រសួងត្រូវជម្រុញសកម្មភាពមួយចំនួនដូចខាងក្រោម :

- បន្តអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋាននានាដែលទាក់ទងទៅនឹងការអនុវត្ត កាតព្វកិច្ចហ្វឹកហ្វឺនកូនជាង

- ត្រួតពិនិត្យសមត្ថភាពកម្មករចាស់ៗ
- ធ្វើការហ្វឹកហ្វឺនកូនជាងនិងផ្តល់វិញ្ញាបនបត្រ/ប័ណ្ណទទួលស្គាល់សមត្ថភាពជំនាញ
- ធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាង
- កសាងលិខិតបទដ្ឋាន ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ។

### ១១២. ការផ្តល់សេវាអប់រំពិសេស

សំដៅផ្តល់ចំណេះដឹង និងជំនាញជូនដល់បុគ្គលដែលមានតម្រូវ-ការពិសេស ដូចជាជនដែលមានលក្ខណៈសម្បត្តិខ្សោយខាងគំនិតបញ្ញាស្មារតី ឬបញ្ហាខាងវិញ្ញាណ ជនពិការភាព ជាពិសេសជនជាតិភាគតិចកម្មវិធីសិក្សាត្រូវរៀបចំឱ្យបានសមស្របទៅតាមតម្រូវការពិសេសរបស់ក្រុមមុខសញ្ញានីមួយៗ ធ្វើយ៉ាងណាឱ្យពួកគាត់មានលទ្ធភាពទទួលបានជំនាញ អាចយកទៅប្រកបមុខរបរបាន ព្រមទាំងអាចរួមរស់ក្នុងសង្គម ជានដូចបុគ្គលធម្មតា ។

- សិក្សាពីតម្រូវការពិសេស
- រៀបចំកម្មវិធីសិក្សា សំរាប់អប់រំបណ្តុះបណ្តាលជំនាញដែលក្រុមមុខសញ្ញាចង់បាន
- បើកវគ្គបណ្តុះបណ្តាលដល់ក្រុមមុខសញ្ញា ។

### ១១៣. ការបណ្តុះបណ្តាលក្រោមគម្រោងមូលនិធិជាតិបណ្តុះបណ្តាល

ពង្រីកកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរយៈការអនុវត្តមូលនិធិជាតិបណ្តុះបណ្តាល ឱ្យចូលដល់មូលដ្ឋានភូមិ ឃុំ-សង្កាត់ ហើយឆ្លើយតបបានទៅនឹងតម្រូវការក្នុងគម្រោងភូមិមួយផលិតផលមួយដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ សកម្មភាពដែលត្រូវអនុវត្តរួមមាន ៖

- គៀងគររកជំនួយបន្ថែមទៀត
- ពង្រាយកម្មវិធីបណ្តុះបណ្តាលដល់ទីជនបទដាច់ស្រយ៉ាលបានគ្រប់ខេត្ត-ក្រុង
- ជម្រុញឱ្យអ្នកផ្តល់ការបណ្តុះបណ្តាលផ្នែកឯកជន មានការចូលរួមកាន់តែច្រើន ។

## 1.4- *ការបណ្តុះបណ្តាលតាមប្រព័ន្ធលិខិតបញ្ជាក់*

ជម្រុញបន្ថែមទៀតឱ្យមាន ការបណ្តុះបណ្តាលរបៀបនេះបានគ្រប់ ២៤ខេត្ត-ក្រុង ដើម្បីឈានដល់សម្រេចគោលដៅនៃការអនុវត្តវិមជ្ឈការកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានភូមិ ឃុំ-សង្កាត់នីមួយៗ ជាអ្នកលើកឡើងនូវផែនការ និងតម្រូវការបណ្តុះបណ្តាល ។ សព្វថ្ងៃនេះ ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបាននឹងកំពុងអនុវត្តនូវខេត្តកំពត និងបាត់ដំបង ហើយបន្ថែម ៥ខេត្តទៀត ( តាកែវ ស្វាយរៀង ស្ទឹងត្រែង កំពង់ឆ្នាំង និងសៀមរាប ) ក្នុងឆ្នាំ ២០០៧ និងបញ្ចប់វិញនៅឆ្នាំ ២០០៩ ។

យើងនឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីរកជំនួយសម្រាប់អនុវត្តកម្មវិធីនេះបន្ត ព្រោះថាការបណ្តុះបណ្តាលតាមប្រព័ន្ធលិខិតបញ្ជាក់មានលក្ខណៈទន់ភ្លន់ ហើយ

ផ្សារភ្ជាប់ជាមួយមុខរបរតាមគ្រួសារ សហគមន៍នីមួយៗនូវបច្ចេកវិទ្យាថ្មីៗ ដែលជួយសម្រួលដល់ផលិតផលកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់នាំឱ្យកើនទីផ្សារផលិតផលប្រាក់ចំណូលក៏កើនឡើង និងកាត់បន្ថយ បាននូវភាពក្រីក្រ ។